# ប៊ិកស្មៀន

ព្រឿង ប្រណីត

## The Secretary's Pens

By Proeung Pranit

បច្ចុប្បន្នលោករស់នៅភូមិ-ឃុំសំរោង ស្រុកសំរោង ខេត្តឧត្តរមានជ័យ។ ស្នាដៃសំខាន់ៗមានកំណាព្យទឹកភ្នែកក្រហម,វប្បធម៌រលត់ជាតិរលាយ វប្បធម៌ពណ្ណរាយជាតិថ្កើងថ្កាន។ កំណាព្យរឿងប្រណីតសិលា, ហួសពេលយំ។ នៅឆ្នាំ២០០៦នេះ លោកបានទទួលចំណាត់ ថ្នាក់លេខ ៣ ផ្នែកកំណាព្យ ពីសមាគមអក្សរសិល្ប៍ន្ធ ហាច មាន ចំណងជើងថា៖ *ប៊ិកស្មៀន, សែនស្រណោះ, ឡានថ្លៃ។*

*ប៊ិកអើយប៊ិកស្មៀន ប៊ិកអភ័ព្វ*
*ខំប្រឹងស្មើរផាប់រៀងរាល់ថ្ងៃ*
*ព្រលឹមព្រលប់ឥតឈប់ដៃ*
*មកពីតម្លៃឬយ៉ាងណា?*
*ឯប៊ិកលោកខ្វះហាក់ទំនេរ*
*ចាំតែស៊ីញេ ចាំតែថា*
*ទោះជិតលើអ្វីក៏បានការ*
*ភោគផលសក្ដាចូលហួសស្មាន។*
*ប៊ិកស្មៀនប៊ិកគ្មានគេអាណិត*
*ជួនបាយថ្ងៃត្រង់ត្រូវខកខាន*
*ជួនស្តីបន្ទោសថាយឺតយូរ*
*ជួនត្រចៀកស្រាលស្តាប់មិនច្បាស់*
*អនិច្ចា! ស្មៀនខំគ្មានសម្រាក*
*ផុតពីស៊ីញេមេប្រមូល*
*ជួនកាលស្មៀនខ្វាចហាក់ស្ទាក់ស្ទើរ*
*សម័យនេះហើយត្រូវតែហ៊ាន*

*ខំចារខំក្រិតញើសជោកប្រាណ*
*គិតខាងតែបានគាប់ចិត្តម្ចាស់។*
*ជួនថាបន្ទូរមិនគាបខ្វះ*
*គេចោទផ្ដេសផ្ដាសជៀលត្រកូល។*
*ការងារគ្មានស្រាកប្រាក់គ្មានចូល*
*បញ្ចូលទាំងអស់រំលងស្មៀន។*
*គេជៀលថាភ្លើមិនចេះរៀន*
*អត់យើងនៅមានអ្នកហ៊ានធ្វើ៕*